សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារូ យូជិ**

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង

សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

០៧ មិនា ២០១៤

- **សូមគោរព លោកស្រី ម៉ាត់ស៊ូរ៉ា អាយូមី នាយិកាអង្គការអាយ.វី.វ៉ាយ!**
- **សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយណាស់ដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន សម្រាប់គម្រោងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទតាមរយៈការបង្កើតនូវការគ្រប់គ្រងដែលមាននិរន្តរភាពក្នុងសហគមន៍ផ្គត់ផ្គង់កសិផលស្វាយរៀង(SAC) ដំណាក់កាលទីពីរ។

ការពង្រឹងវិស័យកសិកម្មគឺជាគោលដៅមួយដ៏សំខាន់សម្រាប់អនាគតរបស់ប្រទេសកម្ពុជាដែលជាប្រទេសកសិកម្មមួយ ហេតុដូចនេះហើយបានជារាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យនេះជាមុំមួយក្នុងបណ្តាមុំទាំងបួននៃយុទ្ធសាស្ត្រចតុកោណដើម្បីអភិវឌ្ឍន៍ជាតិ។ ដោយអនុលោមតាមគោលការណ៍នេះរដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្តល់ការគាំទ្រដល់វិស័យកសិកម្មនៅប្រទេសកម្ពុជាតាមរយៈការកែលម្អនិងស្តារប្រព័ន្ធធារាសាស្ត្រ ការផ្តល់ជំនួយផ្នែកបច្ចេកទេសសម្រាប់អភិវឌ្ឍន៍ ការគ្រប់គ្រងផ្នែកកសិកម្មដោយជំនួយអភិវឌ្ឍន៍ផ្លូវការនានា។ យ៉ាងណាមិញ សេវាគមនាគមន៍ ការប្រមូលនិងដឹកជញ្ជូនកសិផលនៅមានកម្រិតនៅឡើយដែលយើងសង្ឃឹមថាគម្រោងនេះនឹងជួយគាំទ្របន្ថែមដល់បញ្ហានេះ។

អ្វីដែលពិសេសសម្រាប់ឆ្នាំនេះ គឺសហគមន៍កសិកម្មកម្ពុជាដែលជាដៃគូនឹងទទួលបានការបណ្តុះបណ្តាលបច្ចេកទេសថ្មីៗតាមរយៈអ្នកបច្ចេកទេសJICA។ ប្រទេសកម្ពុជាធ្លាប់ជាសហគមន៍កសិកម្មដ៏សកម្មមួយក្នុងកំឡុងទស្សវត្សឆ្នាំ១៩៥០និង១៩៦០ ប៉ុន្តែក្នុងកំឡុងទស្សវត្សឆ្នាំ១៩៧០កិច្ចសហប្រតិបត្តិការកសិកម្មទាំងអស់ត្រូវបានបញ្ចប់ដោយសារអស្ថេរភាពដែលបណ្តាលមកពីសង្គ្រាមផ្ទៃក្នុង និងភាពអសកម្មក្នុងសម័យប៉ុលពត។ មកដល់បច្ចុប្បន្ន ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា កិច្ចសហប្រតិបត្តិការកសិកម្មក៏បានងើបឡើងវិញជាលំដាប់ ហើយគិតមកដល់ឆ្នាំ២០១៣នេះ សហគមន៍កសិកម្មប្រមាណ៤០០ត្រូវបានបង្កើតឡើង ប៉ុន្តែសកម្មភាពមួយចំនួន តួយ៉ាងការដឹកជញ្ជូនកសិផលនៅមានកម្រិតនៅឡើយដែលទាមទារឲ្យមានការជួយគាំទ្រជាបន្ទាន់ដើម្បីលើកស្ទួយសហគមន៍កសិកម្មទាំងនោះ និងជំរុញការអភិវឌ្ឍវិស័យកសិកម្ម។

តាមរយៈគម្រោងនេះ អង្គការ អាយ.វី.វ៉ាយ នឹងជួយគាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាពម្ចាស់ការរបស់សហគមន៍ផ្គត់ផ្គង់កសិផលស្វាយរៀង(SAC)។ ខ្ញុំបានទទួលដំណឹងថា ក្នុងតំណាក់កាលទីមួយនៃគម្រោងនេះ យើងទទួលបានជោគជ័យច្រើនជាងអ្វីដែលបានរំពឹងទុក ទាំងការដឹកជញ្ជូនកសិផល និងប្រាក់ចំណូល ព្រមទាំងការគ្រប់គ្រងបែងចែកប្រភេទបន្លែគ្មានសារធាតុគីមី។ ប៉ុន្តែ ការគ្រប់គ្រងសហគមន៍នៅមានកម្រិតនៅឡើយ ដែលជាមូលហេតុសំខាន់តម្រូវឲ្យ អាយ.វី.វ៉ាយ. ត្រូវបន្តដំណាក់កាលទីពីរនៃគម្រោងនេះ។

គម្រោងនេះមានគោលដៅលើកស្ទួយផលិតកម្មបន្លែធម្មជាតិ មិនប្រើសារធាតុគីមី និង ធ្វើឲ្យមាននូវនិរន្តរភាពក្នុងបណ្តាញផ្គត់ផ្គង់ ហើយជាងនេះទៅទៀត គឺដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាពរបស់សហគមន៍ផ្គត់ផ្គង់កសិផលស្វាយរៀង(SAC)ដើម្បីឲ្យសហគមន៍នេះមានលទ្ធភាពបន្តប្រតិបត្តិការដោយខ្លួនឯងប្រកបដោយនិរន្តរភាពនៅពេលគម្រោងនេះត្រូវបានបញ្ចប់។

ដោយមានការជ្រោមជ្រែងពីអង្គការអាយ.វី.វ៉ាយ បច្ចុប្បន្ននេះសហគមន៍បានផ្គត់ផ្គង់ទៅដល់ហាងបន្លែជាច្រើននៅរាជធានីភ្នំពេញនូវបន្លែធម្មជាតិ មិនមានសារធាតុគីមីរបស់ពួកគេ។ ដោយផ្ទុយពីការពិតដែលប្រជាជនខេត្តស្វាយរៀងប្រមាណ៩០%ជាកសិករ មានប្រជាជនជាច្រើនបានធ្វើចំណាកស្រុកទៅស្វែងរកការងារធ្វើនៅភ្នំពេញ។ យើងសង្ឃឹមថា តាមរយៈការបង្កើតសហគមន៍ផ្គត់ផ្គង់កសិផលក្នុងខេត្តស្វាយរៀងនេះ ប្រជាជនដែលកំពុងធ្វើចំណាកស្រុកទៅធ្វើការនៅភ្នំពេញហើយដោយសារតែប្រាក់បៀវត្សទាបអាចវិលត្រឡប់មកចូលរួមក្នុងវិស័យកសិកម្ម និងនេសាទវិញដោយសារតែមានការផ្លាស់ប្តូរបណ្តាញផ្គត់ផ្គង់កសិផលនេះ។ យើងសង្ឃឹមយ៉ាងមុតមាំថា តាមរយៈគម្រោងនេះ សហគមន៍SACនឹងអាចដាំដុះបន្លែធម្មជាតិមិនមានសារធាតុគីមី ព្រមទាំងមានបណ្តាញផ្គត់ផ្គង់ដោយខ្លួនឯងប្រកបដោយនិរន្តរភាព ហើយសហគមន៍SACនឹងក្លាយជាគំរូមួយសម្រាប់សហគមន៍ផ្គត់ផ្គង់កសិផលក្នុងប្រទេសកម្ពុជា។

ជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានផ្តល់ជូនអង្គការក្រៅរដ្ឋាភិបាលជប៉ុនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជននៅកម្រិតមូលដ្ឋាន។ ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះនឹងផ្តល់អត្ថប្រយោជន៍ផ្ទាល់ដល់ប្រជាជននៅក្នុងតំបន់គោលដៅ ព្រមទាំងរួមចំណែកជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងជប៉ុន និង កម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!